ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៣៤២៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើចំណាត់ថ្នាក់ជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ដីដែលមានទីតាំងស្ថិតនៅក្នុងភូមិសាស្ត្រក្រុងបាត់ដំបងនិងស្រុកសង្កែ ខេត្តបាត់ដំបង សម្រាប់អភិវឌ្ឍអាកាសយានដ្ឋានបាត់ដំបង លំដាប់ថ្នាក់ 4C

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២៣/០២០ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៨/០០៣ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអាកាសចរស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២១០/០០៣ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអស្សាមិករណ៍
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា១ .-**

ត្រូវបានធ្វើចំណាត់ថ្នាក់ជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ដីសម្រាប់ពង្រីកនិងអភិវឌ្ឍអាកាសយានដ្ឋាន

បាត់ដំបង លំដាប់ថ្នាក់4C ដែលមានផ្ទៃដីសរុបទំហំ ២០២,២២ ហិកតា (ពីររយពីរហិកតា និងម្ភៃពីរអា) ដែលមានទីតាំងស្ថិតនៅក្នុងភូមិសាស្ត្រក្រុងបាត់ដំបងនិងស្រុកសង្កែ ខេត្តបាត់ដំបង ដូចមានផែនទីនិងប្លង់បង្ហាញទីតាំង ភ្ជាប់ជាឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ និងមាននិយាមកាដូចខាងក្រោម៖

| | | | | | |
|---|---|---|---|---|---|
| (C1) | 3 07 031.110 E | 14 47 779.310 N | (C7) | 3 08 619.835 E | 14 48 509.512 N |
| (C2) | 3 06 980.280 E | 14 47 784.710 N | (C8) | 3 08 687.118 E | 14 48 330.756 N |
| (C3) | 3 06 545.502 E | 14 47 945.647 N | (C9) | 3 07 925.296 E | 14 48 044.009 N |
| (C4) | 3 06 446.514 E | 14 48 208.635 N | (C10) | 3 07 293.160 E | 14 47 753.010 N |
| (C5) | 3 09 722.162 E | 14 49 441.572 N | (C11) | 3 07 049.600 E | 14 47 831.810 N |
| (C6) | 3 09 892.659 E | 14 48 988.597 N | | | |

**មាត្រា២ .-**

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ជាអាជ្ញាធរកាន់កាប់ដីសាធារណៈរបស់រដ្ឋដូចមានកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះ ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាននិងគោលការណ៍កំណត់របស់រាជរដ្ឋាភិបាល។

**មាត្រា៣ .-**

ត្រូវបានហាមឃាត់រាល់សកម្មភាពចូលកាន់កាប់ សាងសង់ ដោះដូរ ទិញលក់ ឬផ្ទេរសិទ្ធិឬកម្មសិទ្ធិតាមគ្រប់រូបភាពលើដីដែលបានកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះ លើកលែងតែសកម្មភាពនោះទទួលបានការអនុញ្ញាតពីគណៈកម្មការអន្តរក្រសួងសិក្សាអំពីលទ្ធភាពស្តារនិងអភិវឌ្ឍអាកាសយានដ្ឋានបាត់ដំបងលំដាប់ថ្នាក់4C។

**មាត្រា៤ .-**

ម្ចាស់កម្មសិទ្ធិនិងអ្នកកាន់កាប់ស្របច្បាប់លើដីដែលបានកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះ ត្រូវទទួលបានសំណង ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៥ .-**

ប្លង់ស្តីពីការគ្រប់គ្រងកម្ពស់ឧបសគ្គអាកាសយានដ្ឋានបាត់ដំបង សម្រាប់សុវត្ថិភាពហោះហើរនៃអាកាសយានដ្ឋាន នឹងត្រូវបញ្ចូលក្នុងរាល់ឯកសារនគរូបនីយកម្មនានា ដោយគោរពតាមបទដ្ឋានបច្ចេកទេសហោះហើរ ដូចមានចែងក្នុងឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ។

**មាត្រា៦ .-**

បុគ្គលដែលប្រព្រឹត្តល្មើសនឹងមាត្រា៣នៃអនុក្រឹត្យនេះ ត្រូវទទួលទណ្ឌកម្មតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៧ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៨ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១២រោច ខែ អស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធទី១**
នៃអនុក្រឹត្យលេខ ៣៦៨ អនក្រ.បក
ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០២៣

**ផែនទីបង្ហាញទីតាំងផ្ទៃដីសម្រាប់អតិថិជ្ឈអាកាសយានដ្ឋានបាត់ដំបង លំដាប់ថ្នាក់ 4C ស្ថិតនៅក្នុងភូមិសាស្ត្រក្រុងបាត់ដំបងនិងស្រុកសង្កែ ខេត្តបាត់ដំបង**




តារាងនិយាមការព្រំដី ២០២.២២៣៣ ហិកតា / Projection UTM, Zone 48, Datum WGS-84

| ចំណុចព្រំ | E | N | សេចក្តីផ្សេងៗ |
|---|---|---|---|
| C1 | 3 07 031.110 | 14 47 779.310 | ព្រំចាស់ |
| C2 | 3 06 980.280 | 14 47 784.710 | ព្រំចាស់ |
| C3 | 3 06 545.502 | 14 47 945.647 | ព្រំចាស់ |
| C4 | 3 06 446.514 | 14 48 208.635 | ព្រំចាស់ |
| C5 | 3 09 722.162 | 14 49 441.572 | ព្រំថ្មី |
| C6 | 3 09 892.659 | 14 48 988.597 | ព្រំថ្មី |

| ចំណុចព្រំ | E | N | សេចក្តីផ្សេងៗ |
|---|---|---|---|
| C7 | 3 08 619.835 | 14 48 509.512 | ព្រំចាស់ |
| C8 | 3 08 687.118 | 14 48 330.756 | ព្រំថ្មី |
| C9 | 3 07 925.296 | 14 48 044.009 | ព្រំចាស់ |
| C10 | 3 07 293.160 | 14 47 753.010 | ព្រំចាស់ |
| C11 | 3 07 049.600 | 14 47 831.810 | ព្រំចាស់ |

**ឧបសម្ព័ន្ធទី២**
នៃអនុក្រឹត្យលេខ ៣២៨ អនក្រ.បក
ចុះថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ២០២៣

## ប្លង់បន្ទាញទីតាំងតំបន់គ្រប់គ្រងកម្ពស់ឧបសគ្គអាកាសយានដ្ឋានបាត់ដំបង លំដាប់ថ្នាក់ 4C ស្ថិតនៅក្នុងភូមិសាស្ត្រក្រុងបាត់ដំបងនិងស្រុកសង្កែ ខេត្តបាត់ដំបង




**Note :**
1- Runway : 2500mx45m ; height ±0m ; elevation 18m
2- Runway Strips : 2620mx300m; height ±0m
3- Approach Slope Section : length 7500m ; slope 2% ; height 0 ÷ 150m
4- Approach Horzontal Section : length 7500m; height 150m
5- Take-off Climb Surface : length 7500m ; slope 2%; height 0 ÷ 150m
5N- *Take-off Climb Surface : length 9375m ; slope 1.6%; height 0 ÷ 150m (New Structure)*
6- Transitional Surface : width 315m; slope 14.3%; height 0 ÷ 45m;
7- Inner Horizontal Surface : radius 4000m ; height 45m
8- Conical Surface : radius 6000m ; slope 5% ; height 45 ÷ 145m
9- Outer Horizontal Surface : radius 15000m ; height 150m
• Reference Coordinates : UTM, WGS-84
- Runway THR07 : E 3 06 984.918; N 14 48 197.589
- Runway THR25 : E 3 09 324.666; N 14 49 078.259
- Runway strips end 07 (OLS started point, West) : E 3 06 928.764; N 14 48 176.453
- Runway strips end 25 (OLS started point, East) : E 3 09 380.820; N 14 49 099.395

**សម្គាល់ :**
1-ផ្លូវរត់ : 2500mx45m; កម្ពស់ ±0m ; កម្រិតកម្ពស់ 18m (ពីផ្ទៃទឹកសមុទ្រ)
2-វាលអមផ្លូវរត់ : **2620mx300m** ; កម្ពស់ ±0m
3-ផ្ទៃជម្រាល នៃ ផ្លូវហោះចុះ : បណ្ដោយ 7500m ; ជម្រាល 2% ; កម្ពស់ 0 ÷ 150m
4-ផ្ទៃរាប នៃ ផ្លូវហោះចុះ : បណ្ដោយ 7500m ; កម្ពស់ 150m
5-ផ្ទៃផ្លូវហោះឡើង : បណ្ដោយ 7500m ; ជម្រាល 2% ; កម្ពស់ 0 ÷ 150m
5N- *ផ្ទៃផ្លូវហោះឡើង : បណ្ដោយ 9375m ; ជម្រាល 1.6% ; កម្ពស់ 0 ÷ 150m ( សម្រាប់សំណង់ថ្មី)*
6-ផ្ទៃចំណោត : ទទឹង 315m; ជម្រាល 14.3%; កម្ពស់ 0 ÷ 45m;
7-ផ្ទៃរាបក្នុង : កាំរង្វង់ 4000m ; កម្ពស់ 45m
8-ផ្ទៃសាជី : កាំរង្វង់ចន្លោះ 4000m ÷ 6000m ; ជម្រាល 5% ; កម្ពស់ 45m ÷ 145m
9-ផ្ទៃរាបក្រៅ : កាំរង្វង់ 15000m ; កម្ពស់ 150m
• និយាមកាចំណុចយោង : ចំណុចចុងវាលអមផ្លូវរត់ ចម្ងាយ 60m ពីចុងផ្លូវរត់
- ចុងវាលអមផ្លូវរត់ ទិសលិច : E 3 06 928.764; N 14 48 176.453
- ចុងវាលអមផ្លូវរត់ ទិសកើត : E 3 09 380.820; N 14 49 099.395
- សំណង់ ឬវត្ថុខ្ពស់ៗ នៅក្រៅតំបន់ OLS ត្រូវអនុលោមតាមស្តង់ដារផ្ទៃ PANS-OPS Surface

BBM : Aerodrome OLS - 4C - NPA, 15km 2/2


ឧបសម្ព័ន្ធទី២
នៃអនុក្រឹត្យលេខ ៣២៨ អនក្រ.បក
ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០២៣
ផែនទីបង្ហាញទីតាំងតំបន់គ្រប់គ្រងកម្ពស់ឧបសគ្គអាកាសយានដ្ឋានបាត់ដំបង លំដាប់ថ្នាក់ 4C ស្ថិតនៅក្នុងភូមិសាស្ត្រក្រុងបាត់ដំបងនិងស្រុកសង្កែ ខេត្តបាត់ដំបង
PANS-OPS Surface, TMA
Outer Horizontal Surface
height 150m
Conical Surface
Inner Horizontal Surface
height 45m
R15000
R6000
R4000
R 5000
បាត់ដំបង
• Reference Coordinates : UTM, WGS-84
- Runway THR07 : E 3 06 984.918; N 14 48 197.589
- Runway THR25 : E 3 09 324.666; N 14 49 078.259
- Runway strips end 07 (OLS started point, West) : E 3 06 928.764; N 14 48 176.453
- Runway strips end 25 (OLS started point, East) : E 3 09 380.820; N 14 49 099.395
Aerodrome OLS - 4C - NPA, 15km
1/2

ប្លង់បង្ហាញក្បាលដីបាតផ្ទះគ្រប់គ្រងដោយប្រជាពលរដ្ឋ១៥៥គ្រួសារក្នុងទីតាំងដីអាកាសយានដ្ឋាន ក្រុងបាត់ដំបង ខេត្តបាត់ដំបង
ដែលមានទីតាំងស្ថិតនៅភូមិរំចេក៣_រំចេក៤ សង្កាត់រតនៈ និងភូមិច្រាបវាល_បេង ឃុំអន្លង់វិល ស្រុកសង្កែ ក្រុងបាត់ដំបង ខេត្តបាត់ដំបង



**ឧបសម្ព័ន្ធទី១**
នៃអនុក្រឹត្យលេខ ៣២៨ អនក្រ.បក
ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០២៣

**ប្លង់បន្ទាញទីតាំងផ្ទៃដីសម្រាប់អភិវឌ្ឍអាកាសយានដ្ឋានបាត់ដំបងលំដាប់ថ្នាក់ 4C ស្ថិតនៅក្នុងភូមិសាស្ត្រក្រុងបាត់ដំបងនិងស្រុកសង្កែ ខេត្តបាត់ដំបង**




តារាងនិយាមកាព្រំដី ២០២.២២៣៣ ហិកតា / Projection UTM, Zone 48, Datum WGS-84

| ចំណុចព្រំ | E | N | សេចក្តីផ្សេងៗ |
|---|---|---|---|
| C1 | 3 07 031.110 | 14 47 779.310 | ព្រំចាស់ |
| C2 | 3 06 980.280 | 14 47 784.710 | ព្រំចាស់ |
| C3 | 3 06 545.502 | 14 47 945.647 | ព្រំចាស់ |
| C4 | 3 06 446.514 | 14 48 208.635 | ព្រំចាស់ |
| C5 | 3 09 722.162 | 14 49 441.572 | ព្រំថ្មី |
| C6 | 3 09 892.659 | 14 48 988.597 | ព្រំថ្មី |

| ចំណុចព្រំ | E | N | សេចក្តីផ្សេងៗ |
|---|---|---|---|
| C7 | 3 08 619.835 | 14 48 509.512 | ព្រំចាស់ |
| C8 | 3 08 687.118 | 14 48 330.756 | ព្រំថ្មី |
| C9 | 3 07 925.296 | 14 48 044.009 | ព្រំចាស់ |
| C10 | 3 07 293.160 | 14 47 753.010 | ព្រំចាស់ |
| C11 | 3 07 049.600 | 14 47 831.810 | ព្រំចាស់ |